00294880 ឃ 158/4

# នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**សំណុំរឿងលេខ:** ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស

**ឈ្មោះសំណុំរឿង:** ខៀវ សំផន

**ដាក់តម្កល់ជូន:** ការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស)

**កាលបរិច្ឆេទដាក់ឯកសារ:** ៣ មេសា ២០០៩

**ភាគីអ្នកតម្កល់:** ក្រុមការពារក្តី

**ភាសា:** ភាសាដើមជាភាសាបារាំង

**ប្រភេទឯកសារ:** សាធារណៈ

---

## សេចក្តីថ្លែងការណ៍របស់ក្រុមការពារក្តី ដើម្បីឲ្យអនុម័ត យកសំណើសុំបើកកិច្ចស៊ើបសួរលើកទី ១១ របស់លោក នួន ជា ទាក់ទងនឹងការចោទប្រកាន់អំពីបទពុករលួយនៅអ.វ.ត.ក

---

__បញ្ជូនដោយ:__

**មេធាវីរបស់លោក ខៀវ សំផន**

មេធាវី ស សូវាន

មេធាវី Jacques VERGÈS

__បញ្ជូនទៅ:__

**សហចៅក្រមស៊ើបអង្កេត**

លោក យូ ប៊ុនឡេង

លោក Marcel LEMONDE

**ការិយាល័យសហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 03 / APR / 2009
ម៉ោង (Time/Heure): 09:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CA Huy

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 03 / 04 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

1. យើងខ្ញុំដែលមានឈ្មោះដូចតទៅនេះ លោកមេធាវី ស សូវាន និងលោកមេធាវី Jacques VERGÈS សហមេធាវីរបស់ជនត្រូវចោទ លោក ខៀវ សំផន ដែលត្រូវបានដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឃុំខ្លួននៅអ.វ.ត.ក តាំងពីថ្ងៃទី១៨ វិច្ឆិកា ២០០៧មក។

2. ដោយព្រួយបារម្ភយ៉ាងខ្លាំងអំពីការចោទប្រកាន់ពី អំពើពុករលួយនៅអ.វ.ត.ក ដោយបានសង្កេតឃើញពីការបដិសេធពីសំណាក់អាជ្ញាធរមានសមត្ថកិច្ចក្នុងការផ្ដល់ព័ត៌មានសំខាន់អំពីប្រធានបទនេះ និងដោយជឿជាក់ថា មានតែនីតិវិធីប្រកបដោយសមធម៌ ឯករាជ្យ និងមានតម្លាភាពទេ ដែលអាចបម្រើដល់ផលប្រយោជន៍ដល់យុត្តិធម៌ និងការផ្សះផ្សានៅកម្ពុជាបាន។

3. តាមរយៈនេះ យើងខ្ញុំសូមចូលរួមក្នុងសំណើសុំបើកកិច្ចស៊ើបសួរលើកទី ១១ របស់ក្រុមការពារក្ដីលោក នួន ជា ដែលបានដាក់កាលពីថ្ងៃទី២៧ មិនា ២០០៩[1] ដោយយើងខ្ញុំសូមយកតាមពាក្យក្នុងសំណើសុំនេះ និងសូមយ៉ាងទទូចដល់សហចៅក្រមស៊ើបអង្កេតមេត្តា៖ *"ទទួលយកពី អ.ស.ប រាជរដ្ឋាភិបាលកម្ពុជា និង/ឬអង្គការនានា ឬបុគ្គលទាំងឡាយនូវ៖ ក. លទ្ធផលនៃការស៊ើបអង្កេតរបស់ការិយាល័យសេវាកម្មត្រួតពិនិត្យផ្ទៃក្នុង ខ. រាល់លិខិតឆ្លើយឆ្លងរវាង អ.ស.ប និង រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងទៅនឹងការស៊ើបអង្កេតរបស់ការិយាល័យសេវាកម្មត្រួតពិនិត្យផ្ទៃក្នុង និង គ. ព័ត៌មានទាំងឡាយលើកឡើងពីអំពើពុករលួយជាស្ថាប័ន ដែលមានប្រព័ន្ធរៀបចំចាត់ចែងជាមុននៅ អ.វ.ត.ក។ ឯកសារ និងព័ត៌មានបែបនេះ គួរតែត្រូវបានបង្ហាញជូនដល់មេធាវីការពារ និងភាគីដ៏ទៃទៀតដែលមានចំណាប់អារម្មណ៍ ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។ បន្ថែមលើនេះទៀត (...) ក៏សូមគោរពអញ្ជើញក.ស.ច.ស ឱ្យស្នើសុំការបើកកិច្ចស៊ើបសួរផ្ទៃករដ្ឋបាលទៅលើការចោទប្រកាន់ពីអំពើពុករលួយ ដែលមិនទាន់បានដោះស្រាយនៅក្នុងសាលាក្តីនេះនៅឡើយនោះ"*[2]។

[1] សំណើសុំបើកកិច្ចស៊ើបសួរលើកទី ១១ ថ្ងៃទី២៦ មិនា ២០០៩ ដែលបានដាក់តម្កល់នៅការិយាល័យក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី២៧ មិនា ២០០៩ កថាខណ្ឌ២២។ សហមេធាវីកត់សម្គាល់ឃើញថា មកទល់ថ្ងៃនេះ សំណើសុំនេះនៅតែមិនទាន់ត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងនៅឡើយទេ។

[2] សេចក្ដីបកប្រែក្រៅផ្លូវការលើសំណើសុំបើកកិច្ចស៊ើបសួរលើកទី ១១ របស់លោក នួន ជា (ឧបសម្ព័ន្ធ១)

4. ដោយពិចារណាលើធម្មជាតិនៃការចោទប្រកាន់នេះ លើបច្ច័យដែលអាចកើតមានលើការប្រព្រឹត្តទៅនៃការកាត់ក្តី ព្រមទាំងលើភាពចាំបាច់នៃការផ្សព្វផ្សាយជាសាធារណៈអំពីនីតិវិធីបច្ចុប្បន្ន យើងខ្ញុំសូមលោកសហចៅក្រមស៊ើបអង្កេត មេត្តាផ្សព្វផ្សាយលិខិតនេះ និងអត្ថបទសំណើសុំបើកកិច្ចស៊ើបសួរលើកទី ១១ របស់លោក នួន ជា ទាំងស្រុង។

**ក្រោមការរក្សាបទនីយគ្រប់យ៉ាង**
**និងសម្រាប់យុត្តិធម៌**

**មេធាវី ស សូវាន** **មេធាវី Jacques VERGES**